ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១២៧/១០-មីតា បាយអូមេដ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន មីតា បាយអូមេដ (ខេមបូឌា)**

អាសយដ្ឋាន : ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧០៨ ៩២២ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ធូ សារ៉ុធ អ្នកគ្រប់គ្រង

២- កញ្ញា ស៊ុន ស៊ីកានវត្តី រដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **-សហព័ន្ធសហជីពយុវជនខ្មែរ**

**-សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន មីតា បាយអូមេដ**

អាសយដ្ឋាន : ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៤០ ៥៤៨ ទូរសារ : គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

| | |
|---|---|
| ១- លោក ម៉ៃ វឌ្ឍនា | អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ |
| ២- លោក សៀ សន | មន្ត្រីសម្របសម្រួលសហព័ន្ធ |
| ៣- លោកស្រី ស្រី ចន្ថន | ប្រធានសហជីពយុវជនខ្មែរ នៃក្រុមហ៊ុន មីតា បាយអូមេដ |
| ៤- កញ្ញា ស៊ុយ ចាន់ធឿន | អនុប្រធានសហជីព |
| ៥- កញ្ញា អ៊ុំម ប៊ុនធឿន | លេខាធិការសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ៥ ដុល្លា រយៈពេលចំនួន ៥ ខែ សម្រាប់ថ្លៃមធ្យោបាយធ្វើដំណើរទៅកាន់ទីតាំងថ្មី ( ប្តូរពីទីតាំងចាស់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ទៅទីតាំងថ្មី សង្កាត់ចោមចៅ ខណ្ឌដង្កោ វិញ ) ។ ដោយឡែកភាគីក្រុមហ៊ុនអាចផ្តល់ឱ្យបានតែចំនួន ២ ខែ ប៉ុណ្ណោះ ( ក្រុមហ៊ុនបានប្តូរទៅកាន់ទីតាំងថ្មី នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ) ។

២- កម្មករនិយោជិតសុំកុំឱ្យក្រុមហ៊ុនកំណត់ចំនួនផលិតផលឱ្យកម្មករនិយោជិតធ្វើហួសពីសមត្ថភាព និងមិនឱ្យមានការព្រមាន ឬបញ្ឈប់ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនកំណត់ឱ្យកម្មករនិយោជិតធ្វើឱ្យបានចំនួន ២០០០ ដើម ក្នុងមួយថ្ងៃ ជាមធ្យម បើធ្វើលើសពីនេះ ក្រុមហ៊ុនគិតលុយឱ្យបន្ថែមពីលើ បើធ្វើមិនបាន ក្រុមហ៊ុនធ្វើការណែនាំ និងធ្វើការបង្រៀនបន្ថែម ហើយបើកម្មករនោះ ធ្វើការមិនបាន ក្រុមហ៊ុនធ្វើការណែនាំចំនួន ៣ ដង ទើបធ្វើការបញ្ឈប់ ។

៣- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅកូន និងអនុញ្ញាតឱ្យបានសម្រាកចំនួន ១ ម៉ោង ក្នុងមួយថ្ងៃ ដើម្បីបំបៅកូន ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុននឹងធ្វើការសាងសង់នូវទារកដ្ឋាន និងបន្ទប់បំបៅកូនជូនកម្មការិនី ប៉ុន្តែ ក្រុមហ៊ុនមិនអាចបញ្ជាក់កាលបរិច្ឆេទថ្ងៃសាងសង់បានឡើយ ។

៤- ថ្នាក់ដឹកនាំសហព័ន្ធសហជីពយុវជនខ្មែរនៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកកញ្ញា ស្រី ចន្ថន ចូលធ្វើការជាធម្មតាវិញ ( ក្រុមហ៊ុនបានចេញលិខិតបញ្ឈប់ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ) ។ ដោយឡែកភាគីបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកលោកស្រី ស្រី ចន្ថន ឱ្យចូលធ្វើការវិញបានទេ ដោយសារលោកស្រីបានបន្លំឯកសារ ហើយការបញ្ឈប់លោកស្រីនេះ ក្រុមហ៊ុនទូទាត់តាមច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ( អាណត្តិទី៨ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក ) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១០៥៥ ក.ប/អក/វ.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ( វេលាម៉ោង ១៤ : ០០ នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពយុវជនខ្មែរលេខ ៣៧៥ ស.ស.យ.ខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយទទួលលទ្ធផលសះជានឹងគ្នាចំនួន ០៧ ចំណុច លើការទាមទារចំនួន ១១ ចំណុច ។ ចំណុចវិវាទដែលមិនសះជានឹងគ្នាចំនួន ០៤ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១០៥៥ កប/អក/វក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាទាំង ០៤ ចំណុចនេះបន្ថែមទៀត ហើយជាលទ្ធផលភាគីកម្មករនិយោជិត និងនិយោជក បានព្រមព្រៀងគ្នាលើចំណុច

វិវាទទី២ និង ទី៣។ ទន្ទឹមនឹងនេះដែរ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ និយោជក បានជូនដំណឹងមកលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីភាគីកម្មករនិយោជិត និងនិយោជក បានព្រមព្រៀងលើចំណុចវិវាទទី៤ ហើយសុំដក ចំណុចវិវាទនេះពីការទាមទារ។ ដូច្នេះ ចំណុចវិវាទដែលនៅសល់មានតែចំនួន ០១ ចំណុច ប៉ុណ្ណោះ គឺចំណុចវិវាទ ទី១ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា និងដោះស្រាយលើចំណុចនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

៧- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន មីតា បាយអូមេដ ជូនលោក ធី សាវុធ និងកញ្ញា ស៊ុន ស៊ីកានវត្តី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៨- លិខិតឯកភាពរបស់តំណាងសហជីពទ្រទ្រង់កម្មករ តំណាងប្រតិភូបុគ្គលិកពេញសិទ្ធិ និងកម្មករនិយោជិតទាំងអស់នៃក្រុមហ៊ុន មីតា បាយអូមេដ ស្តីពីការទទួលយកនូវការតំឡើងប្រាក់ខែគោលរបស់កម្មករ ៦៥ ដុល្លារ អប្បបរមា ចាប់ពីខែតុលា ឆ្នាំ២០១០ តទៅ និងថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារ ក្នុងមួយខែ រយៈពេលពីរខែ គឺ ខែតុលា និង ខែវិច្ឆិកា ឆ្នាំ២០១០ ។

៩- លិខិតលក់ផ្តាច់លេខ ២០០/១០ ។

១០- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ។

១១- កិច្ចសន្យាជួលអាគារ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១២- វិញ្ញាបនប័ត្របង្កើតរោងចក្រ មីតា បាយអូមេដ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ ។

១៣- លិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ៥០៩៨ ពណ.ចបព ជម្រាបមកលោកនាយកក្រុមហ៊ុន មីតា បាយអូមេដ ស្តីពីការផ្លាស់ប្តូរទីតាំង និងទីតាំងវិនិយោគរបស់ក្រុមហ៊ុន ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០១០ ។

១៤- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ លេខ ៩០១ កប/អក/វក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០១០ ជម្រាបមកអ្នកស្រី ស្រី ចន្ថន ស្តីពីការស្នើសុំចុះបញ្ជិកាសុជីពយុវជនខ្មែរក្រុមហ៊ុន មីតា បាយអូមេដ ។

THE ARBITRATION COUNCIL

១៥- លិខិតរបស់ប្រធាននាយកដ្ឋានអធិការការងារ លេខ ៦៩៣ កប/អក/វក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១០ ជម្រាបមកលោកនាយកក្រុមហ៊ុន មីតា បាយអូមេដ ស្តីពីការប្រើប្រាស់បែបបទស្តីពីសហគ្រាសដែលមានស្រាប់ ។

១៦- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ ។

១៧- ព័ត៌មានលំអិតរបស់ឈ្មោះ ស៊ុយ ចាន់ធឿន ។

១៨- កិច្ចសន្យាការងារសម្រាប់និយោជិតសាកល្បង របស់ឈ្មោះ ស៊ុយ ចាន់ធឿន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៨ ។

១៩- កិច្ចសន្យាបន្ថែម របស់ឈ្មោះ ស៊ុយ ចាន់ធឿន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ។

២០- ឧបសម្ព័ន្ធកិច្ចសន្យាការងារ ។

២១- កិច្ចសន្យាការងារកំណត់ថេរវេលាជាក់លាក់របស់ឈ្មោះ ស៊ុយ ចាន់ធឿន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៩ ។

២២- កិច្ចសន្យាការងារកំណត់ថេរវេលាជាក់លាក់ របស់ឈ្មោះ ស៊ុយ ចាំធឿន ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០០៩ ។

២៣- ព័ត៌មានលំអិតរបស់ឈ្មោះ ស្រី ចន្ទន ។

២៤- កិច្ចសន្យាការងារសម្រាប់និយោជិតសាកល្បង របស់ឈ្មោះ ស្រី ចន្ទន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៩ ។

២៥- កិច្ចសន្យាបន្ថែម របស់ឈ្មោះ ស្រី ចន្ទន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។

២៦- ឧបសម្ព័ន្ធកិច្ចសន្យាការងារ ។

២៧- កិច្ចសន្យាការងារកំណត់ថេរវេលាជាក់លាក់របស់ឈ្មោះ ស៊ុយ ចាន់ធឿន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៩ ។

២៨- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឈ្មោះ ស្រី ចន្ទន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ។

២៩- កិច្ចសន្យាបញ្ចប់ការជួលអាគារ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០ ។

៣០- សេចក្តីប្រកាសផ្ទាល់ខ្លួនអំពីលិខិតថ្កោលទោស របស់ឈ្មោះ ស្រី ចន្ទន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១០ ។

៣១- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ ស្រី ចន្ទន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ។

៣២- សេចក្តីប្រកាសពីលក្ខខ័ណ្ឌការងាររបស់ក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១០ ។

៣៣- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស មីតា បាយអូមេដ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ។

THE ARBITRATION COUNCIL

៣៤- លក្ខន្តិកៈក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៣៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ។

៣៦- អនុសញ្ញារួមស្តីពីការបើកប្រាក់ឈ្នួលរវាងក្រុមហ៊ុន មីតា បាយអូមេដ និងប្រតិភូពេញសិទ្ធិ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៩ ។

៣៧- លិខិតបញ្ឈប់ពីការងារ រវាងក្រុមហ៊ុន មីតា បាយអូមេដ និងអ្នកស្រី ស្រី ចន្ថន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- បង្កាន់ដៃសុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២- លិខិតបញ្ឈប់ពីការងារលោកស្រី ស្រី ចន្ថន ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ។

៣- ប្រវត្តិរូបរបស់ស្រី ចន្ថន ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១០ ។

៤- លក្ខន្តិកៈសហជីពយុវជនខ្មែរ ក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១០ ។

៥- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ៣៨២ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១០ គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសំណើរសុំចុះបញ្ជិកាសហជីព យុវជនខ្មែរ ក្រុមហ៊ុន មីតា បាយអូមេដ ។

៦- កំណត់ហេតុស្តីពីការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហជីពយុវជនខ្មែរ ក្រុមហ៊ុន មីតា បាយ អូមេដ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១០ ។

៧- បញ្ជីឈ្មោះ និងស្នាមមេដៃកម្មការិនីនៃក្រុមហ៊ុន មីតា បាយអូមេដ ទាមទារប្រាក់ថ្លៃជិកជញ្ជូនចំនួន ៥ ខែ ។

៨- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឈ្មោះ ស្រី ចន្ថន ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ។

៩- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរ លេខ ៤៤០ សសយខ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការ ប្តឹងជំទាស់នឹងឯកសាររបស់ក្រុមហ៊ុន មីតា បាយអូមេដ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មីតា បាយអូមេដ លេខ ១០៥៥ ក.ប/ អក/វ.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន មីតា បាយអូមេដ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០១០ ។

THE ARBITRATION COUNCIL

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន មេតាបាយ អូមេដ គឺជាក្រុមហ៊ុនផលិតសម្ភារៈគ្រឿងបរិក្ខាពេទ្យធ្មេញ ដែលបានចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៩ បច្ចុប្បន្នមានជួលកម្មករនិយោជិត ចំនួនប្រហែល ៦២០ នាក់។
- នៅក្នុងក្រុមហ៊ុននេះមានសហជីពចំនួន ២ គឺ សហជីពយុវជនខ្មែរ និងសហជីពទ្រទ្រង់កម្មករ។
- សហជីពយុវជនខ្មែរ គឺជាភាគីដើមបណ្តឹងក្នុងរឿងនេះ។ សហជីពនេះបានបោះឆ្នោត នាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១០។ សហជីពនេះ ទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាពីនាយកដ្ឋានវិវាទការងារនៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១០។ បច្ចុប្បន្ននេះ សហជីពនេះកំពុងស្ថិតរង់ចាំការឆ្លើយតបអំពីសំណុំបែបបទសុំចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ចំណុចវិវាទទី១ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ សម្រាប់ថ្លៃធ្វើដំណើរពីទីតាំងចាស់ នៅសង្កាត់ស្ទឹងមានជ័យ ទៅទីតាំងថ្មី នៅសង្កាត់ចោមចៅ**

- ភាគីនិយោជកបានលើកឡើងថា ក្រុមហ៊ុនបានផ្លាស់ប្តូរពីទីតាំងចាស់ នៅសង្កាត់ស្ទឹងមានជ័យទៅទីតាំងថ្មីនៅសង្កាត់ចោមចៅ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០។ មូលហេតុនៃការផ្លាស់ប្តូរនេះ ដោយសារកិច្ចសន្យាជួលទីតាំងនៅសង្កាត់ស្ទឹងមានជ័យត្រូវដល់កាលកំណត់។ ម្យ៉ាងវិញទៀត ទីតាំងនោះមានលក្ខណៈតូចចង្អៀត។ ហេតុនេះហើយ ទើបក្រុមហ៊ុនសម្រេចផ្លាស់ប្តូរទៅទីតាំងថ្មីដែលមានលក្ខណៈធំទូលាយជាង។ ទាក់ទងទៅនឹងការផ្លាស់ប្តូរទីតាំងនេះ និយោជកបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកម្មកនិយោជិតទាំងអស់ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ ដោយផ្តល់ជូនថ្លៃធ្វើដំណើរចំនួន ០៥ ដុល្លារអាមេរិក រយៈពេល ២ ខែ។ ការផ្លាស់ប្តូរនេះ កម្មករនិយោជិតស្ម័គ្រចិត្ត

THE ARBITRATION COUNCIL

ទៅទីតាំងថ្មីនេះទាំងអស់ ហើយបន្ទាប់ពីមានការផ្លាស់ប្តូរមក មានកម្មករនិយោជិតចំនួនប្រហែលជា ៨០ ភាគរយ បានទៅស្នាក់នៅក្បែរក្រុមហ៊ុន។

- ភាគីកម្មករនិយោជិតបានលើកឡើងថា ចំងាយពីទីតាំងចាស់ទៅទីតាំងថ្មីមានចំងាយប្រហែល ៤ គីឡូម៉ែត្រ។ ពួកគាត់ទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃធ្វើដំណើរចំនួន ០៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ ពោលគឺ សុំចំនួន ៣ ខែ បន្តទៀត។ មូលហេតុនៃការទាមទារនេះ គឺដោយសារទីតាំងថ្មីនៅតំបន់ដាច់ស្រយាល និងកម្មករនិយោជិតពិបាករកផ្ទះជួលនៅទីតាំងថ្មីនោះ ដូចនេះរយៈពេល ៥ ខែ នេះ គឺសមស្របឱ្យកម្មករនិយោជិតមានឱកាសរកទីតាំងថ្មីបាន។ ទន្ទឹមនឹងនេះដែរ នេះ គឺជាកាតព្វកិច្ចផ្នែកផ្លូវច្បាប់ដែលនិយោជកត្រូវតែផ្តល់ជូន។
- ភាគីនិយោជកបានផ្តល់ជូននូវលិខិតជូនដំណឹងស្តីពីការផ្លាស់ប្តូរទីតាំង និងការផ្តល់ជូនថ្លៃធ្វើដំណើរចំនួន ០៥ ដុល្លារអាមេរិកនេះ រយៈពេល ២ ខែ និងមានលិខិតបញ្ជាក់ឯកភាពរបស់កម្មករនិយោជិតដោយមានតំណាងសហជីពទ្រទ្រង់កម្មករ និងតំណាងប្រតិភូបុគ្គលិកផ្តិតមេដៃទុកជាភស្តុតាងដែរ។
- នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតជំទាស់ទៅនឹងភស្តុតាងដែលផ្តល់ជូនដោយភាគីនិយោជកថា ស្នាមផ្តិតមេដៃរបស់កម្មករនិយោជិតទាំងអស់នោះ គឺយល់ព្រមទៅនឹងការតំឡើងប្រាក់ឈ្នួលទេ។ ទាក់ទងទៅនឹងសោហ៊ុយធ្វើដំណើរ គឺនិយោជកគ្រាន់តែប្រាប់ផ្ទាល់មាត់ប៉ុណ្ណោះ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ការទាមទារនេះ គឺសម្រាប់កម្មករនិយោជិតទាំងអស់។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ ភាគីកម្មករនិយោជិតបានផ្តល់លិខិតដែលមានស្នាមមេដៃចំនួនកម្មករនិយោជិត ៤៤ នាក់ ដែលទាមទារសុំថ្លៃធ្វើដំណើររយៈពេល ៥ ខែ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ សម្រាប់ថ្លៃធ្វើដំណើរពីទីតាំងចាស់ នៅសង្កាត់ស្ទឹងមានជ័យ ទៅទីតាំងថ្មី នៅសង្កាត់ចោមចៅ**

ដោយសហជីពពុំទាន់ទទួលបញ្ជិកាសហជីព ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើសហជីពនេះមានសិទ្ធិតំណាងឱ្យកម្មករនិយោជិតចំនួន ៤៤ នាក់ (ដែលអវត្តមាន) ក្នុងការនាំវិវាទការងាររួមមកដោះស្រាយ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល បានដែរ ឬទេ?

មាត្រា ២៦៨ នៃច្បាប់ស្តីពីការងារចែងថា *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ការងារនេះទទួលស្គាល់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនេះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយ*

ARBITRATION COUNCIL

*នាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាលទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីសុំចុះបញ្ជិកា។...*

*ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះថា បានចុះបញ្ជិការួចហើយ..."* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៦៨ ខាងលើនេះមានន័យថា អង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារទទួលស្គាល់ នៅពេលដែលអង្គការវិជ្ជាជីវៈនោះទទួលបានការចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យការងារ ។

ភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ គឺសហជីពយុវជនខ្មែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពនេះបានធ្វើការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១០ បច្ចុប្បន្ននេះ សហជីពយុវជនខ្មែរពុំទាន់ទទួលបានបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ ដូច្នេះ យោងតាមមាត្រា ២៦៨ នៃពីច្បាប់ស្តីពីការងារខាងលើ សហជីពនេះមិនទាន់បានទទួលនូវសិទ្ធិ និងផលប្រយោជន៍តាមច្បាប់ស្តីពីការងារនៅឡើយទេ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដែរថា សិទ្ធិ និងផលប្រយោជន៍នេះ រួមបញ្ចូលទាំងសិទ្ធិរបស់សហជីពក្នុងការតំណាងសមាជិករបស់ខ្លួន មកដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២, លេខ ៣០/០៨-អ៊ី ប្លាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ៣១/០៨-សៅធន់ ប៊ែរ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ១២០/០៩-វីឡាយអេបិល, លេខ ១៦១/០៩ សិប្បកម្មព្រែកព្រែង និងលេខ ៤០/១០-ម៉េង យ៉ាន)* ។

ដូចនេះ សហជីពយុវជនខ្មែរ ពុំមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីយកវិវាទមកដោះស្រាយតាំងនាមឱ្យសមាជិករបស់ខ្លួន នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។

ប៉ុន្តែ ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នក អម...ឬដោយបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

នៅក្នុងករណីនេះ មានកម្មករនិយោជិតចំនួន ៤៤ នាក់ ដែលបានផ្តិតមេដៃ ដើម្បីពឹងពាក់សហជីពយុវជនខ្មែរ ក្នុងការទាមទារនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាតែកម្មករនិយោជិតចំនួន ៤៤ នាក់នេះប៉ុណ្ណោះ ។

តាមរយៈអង្គហេតុ ភាគីកម្មករនិយោជិត និងនិយោជក ពុំមានវិវាទលើចំងាយផ្លូវ ពីការផ្លាស់ប្តូរនេះទេ ប៉ុន្តែ ភាគីទាំងពីរមានវិវាទលើសោហ៊ុយធ្វើដំណើរ ដោយកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមសោហ៊ុយធ្វើ

THE ARBITRATION COUNCIL

ដំណើរចំនួន ៣ ខែបន្ថែមទៀត ពោលគឺ សរុបរយៈពេល ៥ ខែ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតូកិច្ចត្រូវផ្តល់ជូនសោហ៊ុយធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ ដល់កម្មករនិយោជិតចំនួន ៤៤ នាក់ ឬទេ?

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា *" ........នឹងទុកជានិយោជកដែលបង្កើតសហគ្រាស តាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ។ សហគ្រាស... .......... ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក"* ។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គឹកណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១០៨/០៦-ទ្រីនុង ហ្គាល គូមារ៉ា ហេតុផលចំណុចវិវាទទី១ និងលេខ ០៨/០៩-កូប៉ល អាប៉ារែល*)។

ក្នុងសំណុំរឿងលេខ ១៧/០៣ និងលេខ ១៨/០៣-ហ្វូ ហ៊ីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា និយោជកមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន រួមមានការផ្ទេរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយ ហើយនិងការផ្តល់ឱ្យនូវលក្ខខណ្ឌមួយ ចំនួនដូចជា : (១)-មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃ ទៅយប់ ឬពីយប់ មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។ (*សូមមើលបន្ថែមនូវសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦១/០៩-ស៊ុនទ្រី*)។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិត និងនិយោជកពុំមានវិវាទទាក់ទងទៅនឹងចំងាយផ្លូវពីទីតាំងចាស់ទៅទីតាំងថ្មីទេ ភាគីទាំងពីរមានវិវាទតែទៅលើការទាមទារនូវថ្លៃធ្វើដំណើរប៉ុណ្ណោះ។ តាមរយៈអង្គហេតុ និយោជកបានផ្តល់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក ក្នុងរយៈពេល ២ ខែ ប៉ុន្តែ ភាគីកម្មករនិយោជិត សុំទាមទារឱ្យនិយោជកផ្តល់ជូនរយៈពេល ៥ ខែ ដោយលើកមូលហេតុថា ទីតាំងថ្មីនៅតំបន់ដាច់ស្រយាល និងកម្មករនិយោជិតពិបាករកផ្ទះជួលនៅទីតាំងថ្មីនោះ ដូចនេះរយៈពេល ៥ ខែ នេះ គឺសមស្របឱ្យកម្មករនិយោជិតមានឱកាសរកទីតាំងថ្មីបាន។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ *២៩/០៤-ថបវើលដ៍ ហ្គាមិន* ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"ច្បាប់ការងារមិនបានតម្រូវអោយនិយោជកចេញថ្លៃក្នុងការដឹកជញ្ជូនកម្មករជារៀងរាល់ថ្ងៃក្នុងករណីមានការផ្លាស់ប្តូរទីតាំងសហគ្រាសទេ។ ប៉ុន្តែ និយោជកអាចផ្តល់ការដឹកជញ្ជូន ឬផ្តល់ប្រាក់ឧបត្ថម្ភខ្លះ ដើម្បីរក្សាកម្មករនិយោជិត ដែលមានជំនាញស្រាប់អោយធ្វើការនៅក្នុងរោងចក្រដដែល។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការផ្តល់នេះ មិនមែនជាកាតព្វកិច្ចក្នុងច្បាប់ទេ។"*

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅពេលធ្វើការផ្លាស់ប្តូរទីតាំងរបស់ក្រុមហ៊ុន ដើម្បីរក្សាកម្មករនិយោជិតឱ្យបន្តធ្វើការឱ្យក្រុមហ៊ុននិយោជកបានផ្តល់ជូនកម្មករនិយោជិតថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារ អាមេរិក រយៈពេល ២ ខែ។ ក្រុមអាជ្ញាកណ្តាលរកឃើញថា ចម្ងាយពីទីតាំងចាស់របស់ក្រុមហ៊ុន ទៅទីតាំងរបស់ក្រុមហ៊ុនថ្មីនេះ មានប្រវែងប្រហែលជា ៤ គីឡូម៉ែត្រ។ ចម្ងាយនេះ អាចនាំឱ្យមានការលំបាកដល់ការធ្វើដំណើររបស់កម្មករនិយោជិតពីកន្លែងចាស់ ទៅកន្លែងថ្មី ជាពិសេស ចំពោះកម្មករនិយោជិតដែលរស់នៅជិតទីតាំងរបស់ក្រុមហ៊ុនចាស់។ ប៉ុន្តែក្នុងករណីនេះ និយោជក បានផ្តល់ជូនកម្មករនិយោជិតថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក រយៈពេល ២ ខែ ដើម្បីទុកលទ្ធភាពឱ្យកម្មករនិយោជិតស្វែងរកកន្លែងស្នាក់នៅក្បែរទីតាំងថ្មីរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រយៈ ២ ខែ ដែលនិយោជកផ្តល់ជូននេះ ពិតជាអាចផ្តល់ឱកាសឱ្យកម្មករនិយោជិតស្វែងរកទីកន្លែងស្នាក់នៅដែលនៅក្បែរទីតាំងថ្មីរបស់ក្រុមហ៊ុនបាន។ លើសពីនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតតែចំនួន ៨០ ភាគរយ ដែលមានកន្លែងស្នាក់នៅក្បែរទីតាំងថ្មីរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រយៈពេល ២ ខែ គឺជារយៈពេលមួយសមស្របដែលអាចឱ្យកម្មករនិយោជិត រកទីកន្លែងស្នាក់នៅបាន។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិតចំនួន ៤៤ នាក់ ដែលទាមទារឱ្យក្រុមហ៊ុនផ្តល់ចំនួន ៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ សម្រាប់ថ្លៃធ្វើដំណើរពីទីតាំងចាស់របស់ក្រុមហ៊ុន ទៅទីតាំងថ្មីរបស់ក្រុមហ៊ុន។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:** បដិសេធការទាមទាររបស់កម្មករនិយោជិតចំនួន ៤៤ នាក់ ដែលទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក រយៈពេល ៥ ខែ សម្រាប់ថ្លៃធ្វើដំណើរពីទីតាំងចាស់ ទៅទីតាំងថ្មី។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុក រី**

ហត្ថលេខា: ------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------------